**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**លេខ : ០០៦ ម.ម.៥**

ភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥

# វិន័យរបស់កងកម្លាំងនគរបាល

ដើម្បីរក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ជូនប្រជារាស្ត្រឱ្យបានកាន់តែមានប្រសិទ្ធិភាព កងកម្លាំងនគរបាលជាតិគ្រប់ជាន់ថ្នាក់ ត្រូវគោរពប្រតិបត្តិវិន័យឱ្យបានម៉ឺងម៉ាត់ ដែលមានជាអាទិ៍ ដូចខាងក្រោមនេះ ៖

## ប្រការ ១ -កាតព្វកិច្ច សីលធម៌ អាកប្បកិរិយា ៖

១-ត្រូវមានភក្តីភាពចំពោះ ជាតិ សាសនា ព្រះមហាក្សត្រ ។

២-ត្រូវគោរព និងអនុវត្តដោយស្មោះត្រង់តាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល។ បម្រើផលប្រយោជន៍របស់ប្រជារាស្ត្រដោយស្មោះត្រង់ និងមិនធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ប្រជារាស្ត្រឡើយ ។

៣-ត្រូវគោរព និងប្រតិបត្តិយ៉ាងម៉ឺងម៉ាត់ និងដោយសច្ចៈយុត្តិធម៌ចំពោះច្បាប់ បទបញ្ញត្តិ និងបទបញ្ជាផ្សេងៗ ។

៤-ត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនជានគរបាលជាតិ ។

៥-ត្រូវមានអាកប្បកិរិយា សុភាពរាបសារ ថ្លៃថ្នូរ និងម៉ឺងម៉ាត់ក្នុងការងារ ។

៦-ត្រូវរក្សា និងការពារការសម្ងាត់ ជាតិ ក្រសួង និងអង្គភាពខ្លួន ។

៧-ត្រូវស្មោះត្រង់ចំពោះ អង្គភាព មេកើយ និងសហការីរបស់ខ្លួន ។

៨-ត្រូវមានអព្យាក្រឹត្យភាពក្នុងសកម្មភាពការងារ និងមិនត្រូវប្រើប្រាស់មុខងាររបស់ខ្លួន និងសម្ភារៈរបស់រដ្ឋ ដើម្បីបម្រើ ឬ ប្រឆាំងនឹងសកម្មភាពនយោបាយរបស់គណៈបក្សណាមួយឡើយ ។

៩-ហាមដាច់ខាតការចូលបនល្បែងស៊ីសង ដោយគ្មានភារៈកិច្ច ។

## ប្រការ ២-អំពីឯកសណ្ឋាន ៖

១-ត្រូវស្លៀកពាក់ឯកសណ្ឋាន ក្នុងពេលម៉ោងធ្វើការ ឬ បំពេញបេសកកម្ម លើកលែងតែក្នុងករណីដែលមានការកំណត់ផ្សេងពីនេះ ។

ពេលស្លៀកពាក់ឯកសណ្ឋានត្រូវពាក់ឱ្យបានគ្រប់គ្រាន់តាមការកំណត់ និងត្រូវបិទឡេវឱ្យបានសព្វគ្រប់ ។

២-ហាមដាច់ខាតការចូលកំសាន្តក្នុងរង្គសាល និងទទួលទានអាហារ តាមទីសាធារណៈ ក្នុងសម្លៀកបំពាក់ឯកសណ្ឋាន ។

៣-ត្រូវកាត់សក់អោយខ្លី កោរពុកមាត់ ពុកចង្កា និង មិនត្រូវពាក់វែនតាខ្មៅ ។

**ប្រការ៣** .-អំពីការគោរពគំនាប់ :

១-នាយនគរបាល នាយនគរបាលរង ពលនគរបាល ត្រូវគោរពគំនាប់គ្នាទៅវិញ ទៅមក នៅពេលជួបគ្នាតាមរបៀបគោរពគំនាប់របស់កងកម្លាំងប្រដាប់អាវុធ ។

២-ពេលជួបគ្នា អ្នកមានឋានន្តរសក្តិទាបជាង ត្រូវគំនាប់មុន ហើយអ្នកមានឋានន្តរសក្តិខ្ពស់ ក៍ត្រូវគំនាប់តបវិញដែរ ។ ចំពោះអ្នកមានឋានន្តរសក្តិស្មើគ្នា អ្នកឃើញមុនត្រូវលើកដៃគំនាប់មុន ។ ឯមន្ត្រីម្នាក់ទៀត ក៍ត្រូវគំនាប់តបវិញដែរ ។

៣-អ្នកដែលមានឋានន្តរសក្តិខ្ពស់ជាងគេ ត្រូវបញ្ជា "ប្រុង" តាមទីធ្លា និង ត្រូវបញ្ជា " តាមកន្លែងគោរព" ក្នុងបន្ទប់ អោយអ្នកដទៃទៀតដែលនៅជុំវិញខ្លួន និង ត្រូវគំនាប់ ៖

-ពេលមានប្រតិភូអញ្ជើញមកទស្សនកិច្ច ឬ សួរសុខទុក្ខអង្គភាព ។

-ពេលមានថ្នាក់ដឹកនាំជាន់ខ្ពស់អញ្ជើញមក រួមទាំងមន្ត្រីរាជការស៊ីវិល យោធា និង នគរបាល ។

៤-មន្ត្រីនគរបាលដែលមានភារកិច្ចតាមដងផ្លូវ និង ប្រចាំការតាមគោលដៅការពារ ត្រូវគោរពគំនាប់ពេលមានស្គួនរថយន្តប្រតិភូជាផ្លូវការ ឬ មន្ត្រីជាន់ខ្ពស់ឆ្លងកាត់ ។

៥-ពេលប្រតិបត្តិការ ត្រួតពិនិត្យ ដែកឆេះផ្សេងៗ មន្ត្រីនគរបាលជាតិ ត្រូវគំនាប់ចំពោះមុខសញ្ញាដែលខ្លួនបំរុងស្នើសុំ ត្រួតពិនិត្យ ដែកឆេះ ។

៦-ក្នុងករណីពិសេស ត្រូវបានអនុញ្ញាតមិនបាច់គោរពគំនាប់ ដូចមានខាងក្រោមនេះ ៖

-ពេលកំពុងធ្វើដំណើរដោយមធ្យោបាយ កង់ ម៉ូតូ ឬ រថយន្ត ។

-ពេលកំពុងបញ្ជាចរាចរណ៍ ។

-ពេលកំពុងសង្គ្រោះបន្ទាន់ ។

-ពេលកំពុងការពារកន្លែងកើតហេតុ ។

-ពេលកំពុងពន្លត់អគ្គីភ័យ ។

-ពេលកំពុងប្រតិបត្តិការ តាមចាប់ជនល្មើស ។

-ពេលកំពុងបំពេញភារកិច្ច ផ្នែកសន្តិសុខតម្រូវអោយបែរមុខទៅរកសាធារណជន ។

**ប្រការ៤** .-អំពីពេលវេលាការងារ និង ការសុំអនុញ្ញាតច្បាប់ :

១-ត្រូវអនុវត្តអោយបានត្រឹមត្រូវ និង ទៀងទាត់តាមពេលវេលាកំណត់ ៖

-ព្រឹកពីម៉ោង ៧ និង ៣០នាទី ដល់ ម៉ោង ១១ និង ៣០នាទី ។

-ល្ងាចពីម៉ោង ១៤ និង ០០នាទី ដល់ ម៉ោង ១៧ និង ៣០នាទី ។

២-ក្នុងករណីចាំបាច់ មន្ត្រីនគរបាល ត្រូវបំពេញបេសកកម្ម តាមបញ្ជារបស់អង្គភាព ឬ មេកើយ ដោយមិនគិតពីពេលវេលាដែលបានកំណត់ដូចខាងលើឡើយ ។

៣-ក្នុងពេលបំពេញបេសកកម្ម មិនត្រូវទទួលទានគ្រឿងស្រវឹង និង ហាមស្រវឹង ។



គេហទំព័រ ឯកសារមន្ត្រីរាជការ - https://t.me/oa_channel

៤-ការសុំអនុញ្ញាតច្បាប់ឈប់សំរាក ត្រូវអនុវត្តអោយបានត្រឹមត្រូវ តាមបទកំណត់របស់ក្រសួងមហាផ្ទៃ ស្តីពីការកិច្ច និង របៀបរបបធ្វើការងាររបស់ថ្នាក់ដឹកនាំតាមលំដាប់ថ្នាក់នៃក្រសួងមហាផ្ទៃ ។

**ប្រការ៥** .-<u>អំពីទំនាក់ទំនង</u> :

១-នៅពេលមកជួបមេកើយ ឬ មន្ត្រីថ្នាក់លើក្នុងការិយាល័យ មន្ត្រីនគរបាល ត្រូវគោះទ្វារ ដើម្បីសុំការអនុញ្ញាតជាមុន ។ ពេលបានការអនុញ្ញាតហើយ ទើបអាចចូលបាន ។ ត្រូវគំនាប់បើមានមួក និង ប្រើកាយវិការប្រុងបើគ្មានមួក ។ មន្ត្រីនគរបាលទំនាក់ទំនងគ្នាដោយប្រើពាក្យតាមឋានន្តរសក្តិ ។

ត្រូវរាយការណ៍បង្ហាញខ្លួន ជូនថ្នាក់លើដែលមិនមែនជាមេកើយរបស់ខ្លួនផ្ទាល់នូវ ឋានន្តរសក្តិ ឈ្មោះ អត្តលេខ តួនាទី និង អង្គភាពប្រតិបត្តិការ រួចទើបរាយការណ៍ពីខ្លឹមសារការងារដែលត្រូវទាក់ទង ។

ពេលរាយការណ៍ចប់ត្រូវរង់ចាំបញ្ជា និង ត្រូវគំនាប់នៅពេលចប់ទំនាក់ទំនង ។

២-ទំនាក់ទំនងរវាងនគរបាល និង នគរបាលគឺជាទំនាក់ទំនងថ្នាក់លើ ថ្នាក់ក្រោមតាមឋានន្តរសក្តិ ។ មន្ត្រីនគរបាលដែលមានឋានន្តរសក្តិខ្ពស់ជាង មានសិទ្ធិណែនាំដល់មន្ត្រីនគរបាលឯទៀត ដែលមានឋានន្តរសក្តិទាបជាងខ្លួន ដែលបានប្រព្រឹត្តល្មើសនឹងវិន័យ ឬ ក្នុងករណីចាំបាច់ អាចនាំខ្លួននគរបាលនោះមកប្រគល់អោយអង្គភាពមានសមត្ថកិច្ច ឬ អង្គភាពសាមី ។

៣-មន្ត្រីនគរបាលត្រូវបង្គលក្ខណៈងាយស្រួលជានិច្ច ចំពោះប្រតិបត្តិការត្រួតពិនិត្យរបស់ក្រុមតម្រួតបទបញ្ជា។

ក្រុមតម្រួតបទបញ្ជា ត្រូវស្វាហាប់ក្នុងពេលប្រតិបត្តិការ ប៉ុន្តែមិនត្រូវសំដែងនូវប្រការណាមួយ ដែលនាំអោយប៉ះពាល់ដល់កិត្តិយសនគរបាលជាតិឡើយ ។

៤-មិនត្រូវយកមុខងារ ឬ ឋានន្តរសក្តិ ទៅប្រើប្រាស់ដើម្បីគំរាមកំហែង ឬ ធ្វើអោយប៉ះពាល់ដល់កិត្តិយសមន្ត្រីនគរបាលថ្នាក់ទាបជាងខ្លួន ។

៥-ទំនាក់ទំនងរបស់មន្ត្រីនគរបាលជាមួយព្រះសង្ឃ លោកអាចារ្យ ដូនជី ចាស់ព្រឹទ្ធាចារ្យ និង ប្រជារាស្ត្រគ្រប់ស្រទាប់វណ្ណៈ ជានិច្ចជាកាល ត្រូវរួសរាយ រាក់ទាក់ សុភាពរាបសារ មានសុជីវធម៌ និង គោរពប្រពៃណីទំនៀមទំលាប់ នៅតាមតំបន់និមួយៗ ។

**ប្រការ៦** .-<u>អំពីការប្រើប្រាស់អាវុធ</u> :

១-គ្រប់អង្គភាព និង មន្ត្រីនគរបាលគ្រប់ជាន់ថ្នាក់ ត្រូវថែរក្សាអោយបានគង់វង់ រាល់គ្រឿងសព្វាវុធ និង យុទ្ធោបករណ៍ទាំងឡាយដែលបានបំពាក់អោយ ។

២-ការបាត់បង់គ្រឿងសព្វាវុធ និង យុទ្ធោបករណ៍ត្រូវទទួលវិន័យ ឬ ទណ្ឌកម្មតាមច្បាប់កំណត់ ។

៣-រាល់ចលនា កាន់ លើក ដាក់ អាវុធគ្រប់ប្រភេទ ត្រូវអនុវត្តអោយបានត្រឹមត្រូវតាមក្បួនខ្នាតនៃការប្រើ

ប្រាស់អាវុធ ។ ការបង្កអោយមានគ្រោះថ្នាក់ដោយអាវុធ ទោះបីដោយចេតនាក្តី ដោយអចេតនាក្តី មន្ត្រីនគរបាលរូបនោះត្រូវទទួលទោស ឬ ទណ្ឌកម្មតាមច្បាប់ ។

៤-ពេលស្ពាយអាវុធក្នុងរបស់ក្រៅទាន មន្ត្រីនគរបាលត្រូវដាក់កាំភ្លើងខ្លីក្នុងស្រោម ក្រវ៉ាត់នៅចង្កេះខាងស្តាំ ។

៥-មិនត្រូវលក់ ឬ ជួលអាវុធ ។

៦-មិនត្រូវខ្ចី ឬ អោយគេខ្ចីអាវុធយកទៅប្រើប្រាស់ ។

៧-មិនត្រូវលក់ដូរ ឬ ផ្តល់គ្រាប់កាំភ្លើងទៅអោយអ្នកដទៃ ។

៨-មិនត្រូវយកអាវុធទៅគំរាមកំហែងអ្នកដទៃ ។

៩-មិនត្រូវបាញ់កាំភ្លើងដោយគ្មានបញ្ជា លើកលែងតែក្នុងករណីការពារខ្លួនតាមច្បាប់ ឬ ពេលមានអាសន្នត្រូវសង្គ្រោះជីវិតមនុស្ស ឬទ្រព្យសម្បត្តិសាធារណៈ ឬ ឯកជន។

១០-មន្ត្រីនគរបាលដែលស្លៀកពាក់ស៊ីវិលចុះបំពេញបេសកកម្ម ត្រូវសៀតកាំភ្លើងខ្លីខាងក្នុងខោ អាវដោយភាពលាក់បាំង ។

**ប្រការ៧** .-<u>អំពីការបញ្ជា ការអនុវត្តន៍បញ្ជា</u> :

១-មេបញ្ជាការនគរបាលគ្រប់ថ្នាក់ ត្រូវទទួលខុសត្រូវគ្រប់បញ្ជារបស់ខ្លួនចំពោះមុខច្បាប់ និង ចំពោះជោគជ័យ ឬ បរាជ័យក្នុងការអនុវត្តរបស់នគរបាលថ្នាក់ក្រោម ។ បញ្ជាត្រូវធ្វើឡើងអោយបានច្បាស់លាស់ ។

២-អ្នកនៅក្រោមបង្គាប់ ត្រូវអនុវត្តបញ្ជារបស់មេកើយ ដោយគ្មានតវ៉ា ចេញដោលរកហេតុផល ។

៣-គ្រប់ការអនុវត្តន៍បញ្ជា ត្រូវរាយការណ៍វិញជាបន្ទាន់ ជូនមេកើយរបស់ខ្លួនដែលទទួលខុសត្រូវ ។

**ប្រការ៨** .-<u>អំពីការដាក់ទណ្ឌកម្ម</u> :

**ក-គោលការណ៍នៃការដាក់ទណ្ឌកម្ម :**

១-ត្រូវដាក់ទណ្ឌកម្មចំពោះមន្ត្រីនគរបាលជាតិណា ដែលប្រព្រឹត្តខុសវិន័យរបស់កងកម្លាំងនគរបាលជាតិ ។

២-ការដាក់ទណ្ឌកម្មត្រូវបានពិចារណាហ្មត់ចត់ ត្រឹមត្រូវសមស្របតាមទោសកំហុស ដែលមន្ត្រីនគរបាលបានប្រព្រឹត្ត និង មានភស្តុតាងគ្រប់គ្រាន់ ។

៣-ការដាក់ទណ្ឌកម្មតាមរូបភាព អប់រំ ព្រមាន គឺជាសមត្ថកិច្ចរបស់អង្គភាពដែលគ្រប់គ្រងមន្ត្រីនោះផ្ទាល់ ។

៤-រាល់ការដាក់ទណ្ឌកម្មផ្សេងពីចំណុចទី៣ខាងលើ ត្រូវមានការប្រជុំសំរេចពីក្រុមប្រឹក្សាវិន័យស្របតាមការកំណត់របស់ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ។

៥-ការដាក់ទណ្ឌកម្មតាមរូបភាព បន្ថយឋានន្តរសក្តិ ការដកហូតមុខតំណែង ការផ្លាស់ចេញពីអង្គភាព ការបណ្តេញចេញពីក្របខ័ណ្ឌនគរបាល ការបញ្ជូនសំណុំរឿង និង វត្ថុតាងទៅតុលាការវិនិច្ឆ័យទោសគឺជាសមត្ថកិច្ចរបស់ថ្នាក់ ដែលសំរេចតែងតាំង និង បំពាក់ឋានន្តរសក្តិជូនមន្ត្រីរូបនោះ ដោយផ្អែកលើការស្នើតាមឋានានុក្រម ឬ ក្រុមប្រឹក្សាវិន័យ ។

**ខ-បែបបទនៃការដាក់ទណ្ឌកម្ម :**

១-ត្រូវអោយមន្ត្រី ដែលបានប្រព្រឹត្តខុសឆ្គង សរសេរសារណាការពារខ្លួន ដោយខ្លួនឯងផ្ទាល់ ។

២-អង្គភាពគ្រប់គ្រងផ្ទាល់ត្រូវពិនិត្យពិចារណាការខុសឆ្គងនោះ ដើម្បីដាក់ទណ្ឌកម្មអោយបានសមស្រប ។

៣-កំណត់ហេតុ នៃការប្រជុំរបស់ក្រុមប្រឹក្សាវិន័យ ត្រូវដាក់ចូលក្នុងសំណុំឯកសារផ្ទាល់ខ្លួន របស់មន្ត្រីនោះ ។

៤-ការប្រកាសដាក់ទណ្ឌកម្ម មន្ត្រីនគរបាលណាម្នាក់ត្រូវសរសេរអោយបានច្បាស់លាស់អំពីឋានន្តរសក្តិ ឈ្មោះ អាយុ ភេទ មុខតំណែង អង្គភាពដែលសាមីខ្លួនកំពុងបំពេញការងារ កំហុស និង ប្រភេទនៃទណ្ឌកម្មនោះ ។

**គ-ប្រភេទ និង ទំរង់នៃការដាក់ទណ្ឌកម្ម :**

គ-១ ត្រូវដាក់ទណ្ឌកម្មអប់រំ ព្រមានចំពោះមន្ត្រីនគរបាលណាដែល :

១-អវត្តមានឥតច្បាប់ ពី៣ថ្ងៃ ដល់៧ថ្ងៃ ។

២-មិនគោរពពេលម៉ោងធ្វើការទៀងទាត់ ។

៣-ស្រវឹងក្នុងម៉ោងបំពេញការងារ ។

៤-ស្លៀកពាក់ឯកសណ្ឋានមិនត្រឹមត្រូវតាមការកំណត់ ។

៥-បញ្ចេញអាកប្បកិរិយា ឬ ពាក្យសំដី គ្មានសីលធម៌ អមនុស្សធម៌ ខុះសុជីវធម៌ ដែលជាហេតុធ្វើអោយបាត់បង់កិត្តិយស សេចក្តីថ្លៃថ្នូរ របស់នគរបាលជាតិ ។

៦-មិនគោរពអនុវត្តបញ្ជារបស់មេកើយ ។

៧-ទទួលសំណូកចាប់ពី១រៀល ដល់ ៥.០០០រៀល ។

៨-កិបកេងទ្រព្យសម្បត្តិរដ្ឋ ឬ អង្គភាព ពី១០.០០០រៀល ដល់ ១០០.០០០រៀល ។

គ-២ ត្រូវដាក់ទណ្ឌកម្ម បន្ទយឋានន្តរសក្តិ ឬ បណ្តេញចេញពីអង្គភាព ឬ ដកហូតមុខតំណែង ឬ បណ្តេញពីក្របខ័ណ្ឌនគរបាលចំពោះ មន្ត្រីនគរបាលណាដែល :

១-បានទទួលការព្រមានចំនួនពីរដងរួចមកហើយតែមិនព្រមរាងចាល ។

២-អវត្តមានដោយឥតច្បាប់ ពី ៨ថ្ងៃ ដល់ ១៥ថ្ងៃ ។

៣-ផ្ទុះអាវុធដោយគ្មានបញ្ជា ឬ មូលហេតុស្របច្បាប់ ។

៤-ទទួលសំណូកចាប់ពី ៥.០០១រៀល ឡើងទៅ ។

៥-កិបកេងទ្រព្យសម្បត្តិរដ្ឋ អង្គភាព ចាប់ពី ១០០.០០១រៀល ឡើងទៅ ។

៦-យកមុខតំណែង ឋានន្តរសក្តិ សិទ្ធិអំណាចនគរបាលទៅគំរាម កំហែងអ្នកដទៃដើម្បីផលប្រយោជន៍

ផ្ទាល់ខ្លួន ។

៧-ធ្វើលិខិតស្នាមក្លែងក្លាយមិនស្របច្បាប់ ឬ អោយអ្នកដទៃខ្ចីលិខិតរបស់ខ្លួនប្រើប្រាស់ លិខិតស្នាមរបស់នគរបាលជាតិ ។

៨-យកមុខតំណែង ឋានន្តរសក្តិ សិទ្ធិអំណាចនគរបាល ដើម្បីឃុបឃិត ឬ បិទបាំងកំហុស ឬ ធ្វើរបាយការណ៍ កំណត់ហេតុមិនពិត ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន ។

៩-ធ្វើបឯកសារ ឬ សំណុំរឿង ដែលស្ថិតក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួនជាអ្នកដោះស្រាយ ហើយធ្វើអោយយឺតយ៉ាវ ឬ បាត់បង់ ឬ បង្កការលំបាកដល់ប្រជារាស្ត្រ ដល់អង្គភាព ។

១០-យកមធ្យោបាយរបស់រដ្ឋ អង្គភាពទៅប្រើប្រាស់ ដើម្បីទាញយកប្រយោជន៍ផ្ទាល់ខ្លួន ។

១១-បំផ្លាញ ឬ ធ្វើអោយបាត់បង់ ឬ ដោះដូរ ឬ ក្រឡែភាពដើមនៃមធ្យោបាយ សម្ភារៈ ទ្រព្យសម្បត្តិ ឯកសារនានា ដែលជាវត្ថុតាង ស្ថិតក្នុងវង្វង់សមត្ថកិច្ចរបស់ខ្លួនដោះស្រាយ ។

១២-ជាកពិន័យមិនត្រឹមត្រូវ ឬ មិនចេញបង្កាន់ដៃ តាមការកំណត់ ។

១៣-ធ្វេសប្រហែស ធ្វើអោយពិរុទ្ធជន ឬ ទណ្ឌិតរត់រួច ។

១៤-ឃុបឃិតកសាងសំណុំរឿងក្រឡែវត្ថុតាងនានា ដើម្បីសំរាល ឬ ទម្ងន់ ទោស អោយទណ្ឌិត ឬ ពិរុទ្ធជន ។

១៥-សួរចម្លើយដោយ ធ្វើទារុណកម្មគ្រប់រូបភាព កៀបបង្ខំ ឬ បញ្ឆោះចម្លើយ ។

១៦-ធ្វេសប្រហែស ឬ បង្កភាពយឺតយ៉ាវ ក្នុងអន្តរាគមន៍ពន្លត់អគ្គីភ័យ បណ្តាលអោយអន្តរាយដល់អាយុជីវិត ឬ ទ្រព្យសម្បត្តិបន្ថែមទៀត ។

១៧-ចំណាយថវិការដ្ឋមិនត្រឹមត្រូវតាមការកំណត់ ខ្ជះខ្ជាយ ឬ យកថវិការដ្ឋទៅបង្វិល ដើម្បីប្រយោជន៍បុគ្គល ។

១៨-ធ្វេសប្រហែស ខ្វះស្មារតីទទួលខុសត្រូវ ក្នុងការ ការពារអង្គភាព គណៈប្រតិភូជាតិ អន្តរជាតិ ថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិ អន្តរជាតិ បណ្តាលអោយមានគ្រោះថ្នាក់ ។

១៩-បែកការសម្ងាត់របស់អង្គភាព ។

២០-ផ្តល់ពត៌មាន ដោយគ្មានការអនុញ្ញាត ។

គ-៣ ត្រូវបញ្ជូនសំណុំរឿង ទៅតុលាការចំពោះ មន្ត្រីនគរបាលណាដែល ៖

១-បានឃុបឃិត ឬ ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ។

២-លក់អាវុធ ឬ អោយអ្នកដទៃខ្ចីអាវុធប្រើប្រាស់ ។

៣-ផ្តល់គ្រាប់កាំភ្លើងអោយអ្នកដទៃ យកទៅបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ ដល់អាយុជីវិតមនុស្ស ឬ យកទៅធ្វើសកម្មភាពល្មើសច្បាប់ណាមួយ ។

៤-ធ្វើទារុណកម្មធ្ងន់ធ្ងរ ឬ វាយយកចម្លើយ ជនជាប់ចោទ រហូតបាត់បង់ជីវិត ។

៥-អោយបញ្ជាដោយគ្មានមូលដ្ឋានត្រឹមត្រូវក្នុងកិច្ចប្រតិបត្តិការ ដែលបណ្តាលអោយខូចខាតនូវសម្ភារៈ មធ្យោបាយ អាវុធជាតិ ឬ បណ្តាលអោយមានគ្រោះថ្នាក់ ដល់អាយុជីវិតប្រជារាស្ត្រ ។

៦-លួចផ្តល់ពត៌មានសម្ងាត់ អោយខ្មាំង ។

៧-សមគំនិតជាមួយជនអមិត្ត ក្នុងបំណងបំផ្លិចបំផ្លាញសន្តិសុខជាតិ ។

៨-ប្រព្រឹត្តផ្ទុយនឹងចំណុចទី១ ប្រការ១ ដែលមានចែងក្នុងវិន័យនេះ ។

វិន័យនេះមានអានុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

សហរដ្ឋមន្ត្រី

<u>ចម្លងជូន</u>

·ទីស្តីការគណៈរដ្ឋមន្ត្រី

·អគ្គលេខាធិការរាជរដ្ឋាភិបាល

ខុទ្ទកាល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១

ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២

ក្រសួងការពារជាតិ

អគ្គនាយកនគរបាលជាតិ

អគ្គនាយករដ្ឋបាល

គ្គាធិការដ្ឋាន

ាយកខុទ្ទកាល័យ

ប់អភិបាលខេត្ត ក្រុង

ប់ស្នងការនគរបាលខេត្ត ក្រុង

កសារ-កាលប្បវត្តិ